ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៦០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបំពេញបន្ថែម លើអនុក្រឹត្យលេខ១១៥ អនក្រ បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១៧៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមសំណើររបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

www.pheakdeylaw.com

ស ម្រេ ច

មាត្រា១.-

ត្រូវបានបំពេញបន្ថែមក្នុងមាត្រា១២ នៃអនុក្រឹត្យ លេខ១១៥ អនក្រ បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ នូវខ្លឹមសារ ចាប់ពីចំណុចលេខរៀងទី១២-៤ ដូចខាងក្រោម :

មាត្រា១២.-

១២.៤.- សាកលវិទ្យាល័យភូមិន្ទកសិកម្ម មានរចនាសម្ព័ន្ធ ដូចតទៅ :

ក.មហាវិទ្យាល័យ.

.មហាវិទ្យាល័យ វិទ្យាសាស្ត្រកសិកម្ម

.មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ

.មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ

.មហាវិទ្យាល័យវិទ្យាសាស្ត្រជលផល

.មហាវិទ្យាល័យបច្ចេកវិទ្យា និងគ្រប់គ្រងកសិកម្ម

.មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

.មហាវិទ្យាល័យកសិ-ឧស្សាហកម្ម

.មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី

ខ. សាលាក្រោយឧត្តម

គ. ផ្នែកសិក្សា

ឃ. ផ្នែកស្រាវជ្រាវ និងផ្សព្វផ្សាយ

១២.៥.-

ក្នុងករណីចាំបាច់ សាកលវិទ្យាល័យភូមិន្ទកសិកម្ម អាចពង្រីកសមត្ថភាពបង្កើតជំនាញថ្មី បើកថ្នាក់បណ្តុះបណ្តាល អ្នកបច្ចេកទេសកសិកម្មថ្នាក់មធ្យម ក្រោយឧត្តមគ្រប់កំរិត និងថ្នាក់បំប៉នពិសេសផ្សេងៗទៀត ដល់មន្ត្រីរាជការ ប្រជារាស្ត្រ អង្គការជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា តាមរយៈការផ្តល់អាហារូបករណ៍ ឬការបង់ថ្លៃសិក្សា ។

១២.៦.-

ព្រឹទ្ធបុរសមហាវិទ្យាល័យ នាយកសាលាក្រោយឧត្តម នាយកផ្នែក មានឋានៈ ស្មើប្រធាននាយកដ្ឋាន តែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការផ្តល់យោបល់របស់ក្រុមប្រឹក្សាភិបាល ។

១២.៧.-

មហាវិទ្យាល័យ សាលាក្រោយឧត្តម និងផ្នែក មានព្រឹទ្ធបុរសរង និងនាយករង មួយចំនួនជាជំនួយការ ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

១២.៨.-

តួនាទី ភារកិច្ចរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ចាប់ពីថ្នាក់ ក្រោមមហាវិទ្យាល័យ សាលាក្រោយឧត្តម និងផ្នែកចុះ ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

១២.៩.-

សាកលវិទ្យាល័យភូមិន្ទកសិកម្ម អាចបង្កើតសាខា នៅតាមខេត្ត ក្រុងនានា ដើម្បីជួយបំរើផលប្រយោជន៍ ការសិក្សាស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ លើផ្ទៃប្រទេសទាំងមូល ។ សាខានេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ។-

www.pheakdeylaw.com

មាត្រា២.-

ក្រៅពីនេះ ខ្លឹមសារនៃអនុក្រឹត្យលេខ ១១៥ អនក្រ បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ១៩៩៩ នៅរក្សាទុកជាធរមានដដែល ។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com

រចនាសម្ព័ន្ធសាកលវិទ្យាល័យភូមិន្ទកសិកម្ម

ឧបសម្ព័ន្ធអនុក្រឹត្យលេខៈ៦០ អនក្រ.បក
ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤